Khmer

The TB Skin Test (Mantoux)

# ការជោះស្បែកពិសោធរោគរបេង (ម៉ាន់ទូក្ស)

ការជោះស្បែកពិសោធរោគរបេង ឬអង់គ្លេសហៅថា TB skin test ជួនកាលហៅថា “ម៉ាន់ទូក្ស Mantoux” ដែលជារបៀបដ៏ងាយស្រួល ដោយគ្មានធ្វើទុក្ខ ដើម្បីរកឲ្យដឹងថាតើអ្នកមានឆ្លងរោគរបេងមិនទាន់ចេញមុខ ឬអត់ ។



## តើការឆ្លងរោគរបេងមិនទាន់ចេញមុខ មានន័យជាយ៉ាងណា?

ដំណាក់ការនៃរោគរបេងគឺមានពីរ ។ ដំណាក់ការទាំងពីរអាចព្យាបាលបានដោយប្រើថ្នាំពេទ្យ ។ កាលណាមេរោគរបេងបានចូលក្នុងខ្លួនរបស់អ្នកជា ដំបូងនោះវាបណ្តាលឲ្យមានការឆ្លងរោគរបេងមិនទាន់ចេញមុខ ។ បើគ្មានការព្យាបាលទេ ការឆ្លងរោគរបេងមិនទាន់ចេញមុខ អាចក្លាយជាសកម្ម ពីព្រោះវាឆ្លងរាលដាលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត តាមរយៈខ្យល់អាកាស ។

| **ដំណាក់ការទី 1 –**<br>**ការឆ្លងរោគរបេងមិនទាន់ចេញមុខ** | **ដំណាក់ការទី 2 –**<br>**រោគរបេងសកម្ម** |
|---|---|
| មេរោគរបេងគឺវា “ដេកលក់” នៅក្នុងខ្លួនរបស់អ្នក ។ ដំណាក់ការនេះអាចមានរយៈពេលយ៉ាងយូរ –សូម្បីតែមានរយៈពេលជាច្រើនឆ្នាំផង ។ | មេរោគរបេងគឺវាសកម្ម ហើយឆ្លងផង ។ វាធ្វើឲ្យខូចជាលិកានៅក្នុងខ្លួនរបស់អ្នក ។ |
| អ្នកមើលទៅដូចជាគ្មានជំងឺ ឬមានឈឺអ្វីសោះ ។ ការថតអិក្សរេស្មួតរបស់អ្នក គឺមានភាពជាធម្មតា ។ | តាមធម្មតាអ្នកមិនស្រួលខ្លួន ។ គ្រូពេទ្យរបស់អ្នក នឹងធ្វើការពិសោធន៍ ពិសេសដើម្បីរកកន្លែងនៃរោគរបេងដែលកំពុងតែធ្វើទុក្ខក្នុងខ្លួនអ្នក ។ |
| អ្នកមិនអាចចំឡងរោគរបេងទៅមនុស្សផ្សេងទៀតទេ ។ | បើមេរោគរបេងនៅក្នុងសួតរបស់អ្នក នោះអ្នកអាចចំឡងរោគរបេងទៅមនុស្សដទៃ តាមរយៈការក្អក ការកណ្តាស់ ការនិយាយគ្នា និងការច្រៀង ។ |
| តាមធម្មតា បានព្យាបាលដោយលេបថ្នាំពេទ្យចំនួន 9 ខែ ។ | បានព្យាបាល ដោយលេបថ្នាំពេទ្យ 3 ឬ 4 មុខ យ៉ាងតិចបំផុតចំនួន 6 ខែ ។ |

## តើខ្ញុំអាចប្រាប់ ថាតើខ្ញុំមានការឆ្លងរោគរបេងមិនទាន់ចេញមុខដូចម្តេចទៅ?

ការជោះស្បែកពិសោធរោគរបេង (“ម៉ាន់ទូក្ស”) អាចបង្ហាញឲ្យដឹង ក្រែងលោអ្នកមានឆ្លងរោគរបេងមិនទាន់ចេញមុខ។ អ្នកអាចមានរោគរបេងមិនទាន់ចេញមុខ បើអ្នកធ្លាប់បានចំណាយពេល ដោយរស់នៅជិតដិតនឹងនរណាម្នាក់ដែលមានរោគរបេងសកម្ម (ទោះបើអ្នកមិនដឹងថាជននោះមានជំងឺក៏ដោយ) ។

វេជ្ជបណ្ឌិតរបស់អ្នកនឹងប្រើម្ជុលមួយយ៉ាងតូច ដើម្បីចាក់ទឹកថ្នាំខ្លះដែលមិនធ្វើទុក្ខ (គេហៅថា “ទូបីគូលីន”) នៅក្រោមស្បែកដៃរបស់អ្នក ។



**វេជ្ជបណ្ឌិតរបស់អ្នកត្រូវតែ ឆែកមើលដៃរបស់អ្នក នៅក្នុងរយៈពេល 2 ឬ 3 ថ្ងៃ បន្ទាប់ពីបានជោះស្បែកពិសោធរោគរបេង ទោះបើដៃរបស់អ្នកមិនជាថ្វីក៏ដោយ ។**

បើអ្នកមានប្រតិកម្មនឹងការពិសោធន៍ នោះវានឹងឃើញមានឡើងដូចជាសាច់ពក ។ វេជ្ជបណ្ឌិតរបស់អ្នកនឹងវាស់ទំហំនៃការប្រតិកម្ម ។  បើសិនជាមានពកសាច់ នោះវានឹងបាត់ទៅវិញ នៅក្នុងរយៈពេលពីរបីអាទិត្យ ។

## តើខ្ញុំត្រូវថែរក្សាដៃរបស់ខ្ញុំ បន្ទាប់ពីការជោះស្បែកពិសោធរោគរបេងដោយរបៀបណា?

- កុំយកបង់រុំរបួស ឬបង់ស្អិត មកគ្របកន្លែងមុខម្ជុលឲ្យសោះ ។
- ត្រូវប្រុងប្រយ័ត្ន ដោយកុំត្រដុសវា ឬកុំអេះវា ។
- បើសិនជារមាស់នៅកន្លែងមុខម្ជុល នោះយកក្រណាត់សើមត្រជាក់មកដាក់លើវា ។
- អ្នកអាចលាងដៃរបស់អ្នក ហើយសំងួតវាឲ្យស្ងួតដោយថ្នមៗ ។

Adapted from material from the Minnesota Department of Health, TB Prevention and Control Program

# ការជោះស្បែកពិសោធរោគរបេង (ម៉ានទូក្ស)-ទំព័រទី 2

**ចូរកុំខ្លាចពិសោធមើលឲ្យសោះ ។ រោគរបេងអាចព្យាបាលជា!**

## ចុះបើសិនជាការជោះស្បែកពិសោធរោគរបេងរបស់ខ្ញុំ មានលទ្ធផលជាអវិជ្ជមាន?

បើសិនជាគ្មានពកសាច់ (ឬមានពកសាច់យ៉ាងតូច) នៅចំកន្លែងមុខម្ជុល ជាទីដែលពេទ្យបានចាក់ទឹកថ្នាំចូល នោះការពិសោធន៍មានលទ្ធផលជា “អវិជ្ជមាន” គឺមានន័យថាគ្មានរោគ ។ លទ្ធផលជាអវិជ្ជមាននៃការជោះស្បែកពិសោធរោគរបេង តាមធម្មតាគឺមានន័យថាអ្នកពុំមានរោគរបេងឡើយ ។

នៅក្នុងស្ថានការណ៍ខ្លះ អ្នកអាចនឹងត្រូវការជោះស្បែកពិសោធរោគរបេងម្តងទៀត នៅពេលក្រោយ ។

## ចុះបើសិនជាការជោះស្បែកពិសោធរោគរបេងរបស់ខ្ញុំ មានលទ្ធផលជាវិជ្ជមាន?

បើសិនជាមានពកសាច់ នៅកន្លែងមុខម្ជុលដែលពេទ្យបានចាក់ទឹកថ្នាំចូល ដោយមានទំហំជាក់លាក់ នោះការពិសោធន៍មានលទ្ធផលជា “វិជ្ជមាន” គឺមានន័យថាមានរោគ ។ ការនេះគឺមានន័យថាអ្នកប្រហែលជាមានមេរោគរបេងនៅក្នុងខ្លួនរបស់អ្នក ។ មនុស្សភាគច្រើនដែលការជោះស្បែកពិសោធរោគរបេងមានលទ្ធផលជាវិជ្ជមាន គឺបានឆ្លងរោគរបេងមិនទាន់ចេញមុខ ។ ដើម្បីឲ្យបានច្បាស់លាស់ គ្រូពេទ្យរបស់អ្នកនឹងពិនិត្យអ្នក ព្រមទាំងថតសួតរបស់អ្នក ប្រយោជន៍ឲ្យដឹងក្រែងលោអ្នកមានរោគរបេងយ៉ាងសកម្ម ។

**ត្រូវការពារសុខភាពរបស់អ្នក ព្រមទាំងសុខភាពនៃគ្រួសាររបស់អ្នក – សូមពិសោធរករោគរបេង!** ដើម្បីឲ្យមានការជោះស្បែកពិសោធរោគរបេង នោះសូមទាក់ទងជាមួយគ្រូពេទ្យរបស់អ្នក ឬជាមួយក្រសួងសុខភាពសារណៈរបស់អ្នក ។

## អ្នកគួរតែបានជោះស្បែកពិសោធរោគរបេង បើសិនជា :

- អ្នកធ្លាប់បានរស់នៅជិតស្និទ្ធជាញឹកញាប់ ជាមួយនឹងនរណាម្នាក់ដែលមានកើតរោគរបេងសកម្ម
- អ្នកបានរស់នៅក្នុងប្រទេសមួយ ដែលមានមនុស្សជាច្រើនបានកើតរោគរបេង
- អ្នកធ្វើការ ឬរស់នៅមន្ទីរសំរាប់មនុស្សចាស់ជរា (ជរាគិលានុដ្ឋាន) ឬមន្ទីរពិនិត្យរោគ ឬមន្ទីរពេទ្យ ឬព័ន្ធនាគារ ឬទីជំរកសំរាប់អ្នកគ្មានទីលំនៅ ឬក៏
- អ្នកមានឆ្លងរោគ HIV ឬមានបញ្ហាសុខភាពអ្វីមួយ ។

## ចុះបើសិនជាខ្ញុំបានចាក់ថ្នាំ BCG ជាបង្ការ?

ទោះបើអ្នកបានចាក់ថ្នាំ BCG ជាបង្ការក្តី ក៏អ្នកនៅតែអាចជោះស្បែកពិសោធរោគរបេងបានដែរ ។

- មនុស្សដែលបានចាក់ថ្នាំ BCG ជាបង្ការ នៅតែអាចឆ្លងរោគរបេងមិនទាន់ចេញមុខ និងរោគរបេងសកម្ម បានដែរ
- ថ្នាំ BCG ចាក់បង្ការ អាចជួយការពារក្មេងតូចៗ កុំឲ្យគេមានជំងឺធុនដាបដោយសាររោគរបេង ។ ថ្នាំចាក់ការពារនេះនឹងបាត់ទៅនៅពេលមនុស្សធំឡើង
- ថ្នាំ BCG ចាក់បង្ការ ជួនកាលបណ្តាលឲ្យមានប្រតិកម្មនៃការជោះស្បែកពិសោធរោគរបេងជាវិជ្ជមាន ។ ប៉ុន្តែបើអ្នកមានប្រតិកម្មជាវិជ្ជមាន ចំពោះការជោះស្បែកពិសោធរោគរបេង នោះវាប្រហែលជាមកពីមេរោគរបេងនៅក្នុងខ្លួនរបស់អ្នក – គឺមិនមែនមកពីថ្នាំ BCG ចាក់បង្ការ របស់អ្នកឡើយ ។

**ទោះបើអ្នកធ្លាប់បានចាក់ថ្នាំ BCG ជាបង្ការក៏ដោយ គង់តែអ្នកនៅអាចជោះស្បែកពិសោធរោគរបេងបានដែរ!**

Oregon Health Authority

Adapted from material from the Minnesota Department of Health, TB Prevention and Control Program